ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

ឧសភា ២០០៧ / May 2007

ផាន់ ដាលីស / **Phann Dalis**

ហ៊ីង វុត្ថា / **Hing Vutha**

ភឹម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយ: យូ សិទ្ធីរិទ្ធ និង យេន សុផានី

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី១ ២០០៧ គំរោងវិនិយោគឯកជនបានអនុម័តមាន ៤៩៧,៥ លានដុល្លារ រឺថយចុះ ៤៩% ធៀបនឹងត្រីមាសមុន ។ គំរោងបានអនុម័តក្នុងវិស័យសេវាកម្ម និងកសិកម្ម ធ្លាក់ចុះ ៥៥% និង ៨៨% មកត្រឹម ៣៣៥,៧លានដុល្លារ និង ១៩,១លានដុល្លារ ។ រីឯការអនុមតិក្នុងវិស័យឧស្សាហកម្ម កើនបាន ៨៦% ដល់ ១៤២,៧លានដុល្លារ ។ ការអនុមតិគំរោងខាងវិស័យកាត់ដេរ កើន ៤១% ធៀបនឹងត្រីមាសមុន និង ២០% ធៀបនឹងខែដូចគ្នាឆ្នាំ ២០០៥ ដល់ ៣៦,៦លានដុល្លារ។

In the first quarter 2007, private investment approvals were USD 497.5 m, a decrease of 49 percent from the preceding quarter. Service and agriculture approvals declined by 55 percent and 88 percent to USD 335.7 m and USD 19.1 m, respectively, while industry sector approvals increased by 86 percent to USD 142.7 m. Garment sub-sector approvals increased by 41 percent from the previous quarter, and by 20 percent from the same month in 2005, to USD 36.6 m.

**Private Investment Approvals by Sector**
2004 Q3–2007 Q1




*Including expansion projects*
Source: Council for the Development of Cambodia

នៅខែកុម្ភៈ ២០០៧ ភ្ញៀវបរទេសមកដល់កម្ពុជា ធ្លាក់ចុះ ៩,១% ធៀបនឹងខែមុន មកត្រឹម ១៧៧.១៣០នាក់ ។ ភ្ញៀវមកសំរាកលំហែ មាន ១៦១.៩៨៦នាក់ រឺធ្លាក់ចុះ ៣,៤% ។ ខេត្តសៀមរាបទទួលបាន ៦៣% នៃចំនួនភ្ញៀវសរុប ។ ផ្ទុយមកវិញ ចំនួនភ្ញៀវមកដល់សរុប កើនឡើង ១៧% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ក្នុងនេះ ភ្ញៀវមកសំរាកលំហែ កើន ២២% ។

Foreign visitor arrivals to Cambodia in February 2007 decreased by 9.1 percent from the previous month, to 177,130. Visitors on holiday were 161,986, a drop of 3.4 percent. Siem Reap received 63 percent of the total visitors. In contrast, total visitor arrivals were up by 17 percent compared to the same month in 2006. Visitors on holiday rose by 22 percent.

**Cambodia: Foreign Visitor Arrivals**
December 2005 – February 2007




Source: Ministry of Tourism

នៅខែកុម្ភៈ ២០០៧ ការអនុមតិគំរោងសាងសង់នៅក្រុងភ្នំពេញ មានសរុប ១០,៤លានដុល្លារ រឺធ្លាក់ចុះ ៨១% ធៀបនឹងខែមុន ។ ការអនុមតិសំណង់ភូមិគ្រឹះនិងផ្ទះ និងសំណង់ដទៃទៀត ធ្លាក់ចុះ ៥៤% និង ៧៤% មកត្រឹម ២,៦លានដុល្លារ និង ៣,៣លានដុល្លារ ។ ការអនុមតិសំណង់ផ្ទះល្វែង ធ្លាក់ចុះ ៨៧% មកត្រឹម ៤,៥លានដុល្លារ ។ ធៀបនឹងខែដូចគ្នា ២០០៦ ការអនុមតិគំរោងសាងសង់សរុប ធ្លាក់ចុះអស់ ៤៥% ។

Phnom Penh's construction approvals totalled USD 10.4 m in February 2007, a significant fall of 81 percent from the preceding month. Villa and house, and other construction approvals decreased sharply, by 54 percent and 74 percent, to USD 2.6 m and USD 3.3 m, respectively. Approvals for flats fell by 87 percent to USD 4.5 m. By comparison with the same month in 2006, total construction approvals decreased by 45 percent.

**Phnom Penh: Value of Construction Approvals**
November 2005 – February 2007




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់បញ្ញើ

# Consumer Prices and Interest Rates on Deposit

ពីខែកុម្ភៈ ដល់ខែមីនា ២០០៧ ថ្លៃទំនិញទូទៅនៅភ្នំពេញ កើន ០,៥% ។ ក្នុងចំនោមទំនិញ ៨ប្រភេទសំខាន់ៗ ថ្លៃម្ហូបអាហារ កើន ១,០% ហើយ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ០,៥% ។ ធៀបនឹងខែដូចគ្នា ២០០៦ ថ្លៃទំនិញទូទៅ កើន ៣,៥% ក្នុងនោះ ថ្លៃម្ហូបអាហារ កើន ៤,៣% រីឯ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ៥,៨% ។

From February to March 2007, Phnom Penh's overall prices increased by 0.5 percent. Of the eight main categories; food prices, and transportation and communication costs rose by 1.0 percent and 0.5 percent respectively. Compared to the same month in 2006, overall prices were up by 3.5 percent; food prices and transportation and communication costs increased by 4.3 percent and 5.8 percent, respectively.

**Phnom Penh: Consumer Price Index**
(July–December 2000=100)
December 2005 – March 2007




Source: National Institute of Statistics

នៅខែមេសា ២០០៧ ថ្លៃសាំងនៅភ្នំពេញ កើន ២,១% ដោយលក់ថ្លៃ ៣៨០៣រៀល/លីត្រ រីឯថ្លៃម៉ាស៊ូត កើន ១,០% ដោយលក់ថ្លៃ ៣០៧៣រៀល/លីត្រ ។ ធៀបនឹងខែមេសា ២០០៦ ថ្លៃសាំង និងម៉ាស៊ូត កើន ០,០៨% និង ៤,៩% ។

Phnom Penh's petrol prices rose by 2.1 percent in April 2007, selling at 3803 riels/ℓ; whereas, diesel prices increased by 1.0 percent, trading at 3073 riels/ℓ. Both petrol and diesel prices rose by 0.08 percent and 4.9 percent, respectively, from April 2006.

**Phnom Penh: Petrol & Diesel Prices**
February 2006 – April 2007




Sources: CDRI and National Institute of Statistics

អត្រាការប្រាក់រៀល និងដុល្លារ លើប្រាក់បញ្ញើរយៈពេល១២ខែ មិនមានការប្រែប្រួល ចាប់តាំងពីឆ្នាំ ២០០៥ ។ នៅខែកុម្ភៈ ២០០៧ អត្រាការប្រាក់លើបញ្ញើជាប្រាក់រៀល របស់ ធនាគារអេស៊ីលីដា ធនាគារពាណិជ្ជកម្មក្រៅប្រទេស និង ធនាគារកាណាឌីយ៉ា គឺ ៨,០% ៦,៥% និង ៦,០% ។ សំរាប់បញ្ញើជាប្រាក់ដុល្លារ ធនាគារអេស៊ីលីដា និង កាណាឌីយ៉ា មានអត្រាដូចគ្នាគឺ ៦,០% រីឯ ធនាគារពាណិជ្ជកម្មក្រៅប្រទេស មានកំរិត ៥,០% ។

Riel and dollar interest rates on 12-month bank deposits have been unchanged since 2005. In February 2007, interest rates on riel deposits quoted by ACLEDA Bank, Foreign Trade Bank (FTB) and Canadia Bank were 8.0 percent, 6.5 percent and 6.0 percent, respectively. For dollar deposits, both ACLEDA and Canadia offered 6.0 percent, while FTB offered 5.0 percent.

**Interest Rate on 12-Month Bank Deposits**
(As of February 2007)




Source: National Bank of Cambodia.

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស
# Exchange Rates and External Development Assistance

នៅខែមេសា ២០០៧ ប្រាក់រៀលប្តូរបាន ៤០៥៩រៀល/ដុល្លារUS រឺធ្លាក់ចុះ 0,0៦% ធៀបនឹងខែមុន ។ ប៉ុន្តែធៀបនឹងខែដូចគ្នា ២០០៦ ប្រាក់រៀលឡើងថ្លៃ 0,៨% ទល់នឹងដុល្លារUS ។

The riel traded at 4059 riels/USD in April 2007, a depreciation of 0.06 percent from the previous month. Compared to the same month in 2006, however, the riel appreciated by 0.8 percent against the US dollar.

**Riels per US Dollar**
February 2006 – April 2007




Sources: National Bank of Cambodia and CDRI

នៅខែមេសា ២០០៧ ប្រាក់រៀល ធ្លាក់ថ្លៃ 0,៧% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១១៥,៨រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលប្តូរបាន ២៤,៥៦រៀល/១០០ដុង រឺឡើងថ្លៃ 0,២% ។ ចាប់តាំងពីខែមេសា ២០០៦ ប្រាក់រៀល ធ្លាក់ថ្លៃ ៨,២% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃ ១,៤% ទល់នឹងប្រាក់ដុងវៀតណាម ។

In April 2007, riel depreciated by 0.7 percent against Thai bath; the exchange rate was 115.8 riels/baht. Against the Vietnamese dong, riel traded at 24.56 riels per 100 dong, an appreciation of 0.2 percent. The riel depreciated against Thai baht by 8.2 percent but appreciated by 1.4 percent against the Vietnamese dong, since April 2006.

**Riels per THB & VND**
February 2006 – April 2007




Source: CDRI

នៅខែធ្នូ ឆ្នាំ២០០៦ កម្ពុជាបានទទួលកំចី ២៩.៩៣៦ដុល្លារ ពីធនាគារពិភពលោក សំរាប់គំរោងផ្តល់ទឹកនិងអនាម័យនៅតាមខេត្ត និងជាយក្រុង។ កំចីនេះតំណាងឱ្យ ៣,៧% នៃការបើកផ្តល់កំចីសរុប និងតិចជាងកំចីនៅខែដូចគ្នាឆ្នាំ២០០៥ ចំនួន ៨៥% ។ ថវិកាសរុប ២,៨លានដុល្លារ ត្រូវបានបែងចែកសំរាប់គំរោងនេះ នៅឆ្នាំ២០០៦ ហើយថវិកានេះ គឺស្មើ ១៥% នៃការបើកផ្តល់កំចីសរុប និងច្រើនជាងឆ្នាំមុន ៤៣% ។

In December 2006, Cambodia received USD 29,936 from the World Bank in loans to Provincial and Peri-Urban Water and Sanitation Project. This represented 3.7 percent of the total loans disbursement and was 85 percent less than for the same month in 2005. Total funds of USD 2.8 m were allocated to this project in 2006; these fund allocations were 15 percent of the total loans disbursement and 43 percent more than the previous year.

**External Development Assistance Disbursement: Provincial and Peri-Urban Water and Sanitation Project**
November 2005 – December 2006




Source: *Monthly Bulletin of Statistics* (MEF)

# ការអភិវឌ្ឍន៍រូបិយវត្ថុ

# Monetary Developments

នៅខែកុម្ភៈ ២០០៧ រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ៦៧% រីឯការផ្គត់ផ្គង់រូបិយវត្ថុ (M1) កើនតាមអត្រាប្រចាំឆ្នាំ ៣៤% ។ នៅរយៈ ១២ខែមុន រូបិយវត្ថុទូទៅ (M2) កើន ៣៨% ធៀបនឹងកំណើន ៣៩% ក្នុងរយៈមួយឆ្នាំ ដល់ខែមករា ២០០៧ ។

In February 2007, liquidity (M2) grew at an annualised rate of 67 percent and money supply (M1) increased at an annualised rate of 34 percent. In the previous 12 months, liquidity (M2) grew by 38 percent, compared to growth of 39 percent in the year to January 2007.

**Monetary Survey**

December 2005 – February 2007




Source:* Revise. National Bank of Cambodia

នៅខែកុម្ភៈ ២០០៧ ឥណទានក្នុងស្រុក កើនតាមអត្រាប្រចាំឆ្នាំ ៧០% រីឯឥណទានក្នុងវិស័យឯកជន កើនតាមអត្រាប្រចាំឆ្នាំ ៧៧% ។ ក្នុងរយៈ ១២ខែ ដល់ខែកុម្ភៈ ឆ្នាំ២០០៧ ឥណទានក្នុងស្រុក កើន ២៦% ធៀបនឹងកំណើន ៤២% ក្នុងរយៈមួយឆ្នាំ ដល់ខែមករា ២០០៧ ។

Domestic credit grew at an annualised rate of 70 percent, while private sector credit grew at an annualised rate of 77 percent in February 2007. Over the twelve months to February 2007, domestic credit grew by 26 percent, compared to growth of 42 percent in the year to January 2007.

**Domestic Credit**

December 2005 –February 2007




Source: * Revise. National Bank of Cambodia

ឥណទានក្នុងវិស័យឯកជន និងទ្រព្យសកម្មបរទេសសុទ្ធ នៅខែកុម្ភៈ ២០០៧ កើន ៤,៨% ដល់ ៣៩៣២,២ពាន់លានរៀល និង ៤,៩% ដល់ ៧៩៣៧,៧ពាន់លានរៀល ។ ឥណទានរបស់រដ្ឋាភិបាល ធ្លាក់ចុះ ០,៤% មកត្រឹម ២៨៥,១ពាន់លានរៀល រីឯបញ្ញើរបស់រដ្ឋាភិបាល និងបំណុលផ្សេងទៀត កើន ៤,៤% ដល់ ១៣៧០,៦ពាន់លានរៀល និង ៦,០% មកត្រឹម ៣១៦៦,៩ពាន់លានរៀល ។ ប្រតិបត្តិការហិរញ្ញវត្ថុទាំងនេះ បង្កើនរូបិយវត្ថុទូទៅ បាន ៤,៤% ។

Private sector credit and Net Foreign Assets (NFA) in February 2007 grew by 4.8 percent to KHR 3932.2 bn and 4.9 percent to KHR 7937.7 bn, respectively. Government credit decreased by 0.4 percent to KHR 285.1 bn, while government deposits and ‘Other Items’ rose by 4.4 percent to KHR 1370.6 bn and 6.0 percent and KHR 3166.9 bn, respectively. These monetary operations increased liquidity by 4.4 percent.

**Changes in Monetary Assets**

December 2005 – February 2007




Source: *Revise. National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

ការនាំចេញសំខាន់ៗរបស់កម្ពុជា នៅខែកុម្ភៈ ២00៧ កើន ៦,0% ធៀបនឹងខែមុន ដល់កំរិត ២៤៤,២លានដុល្លារ ។ ក្នុងចំណោមការនាំចេញសរុប ការនាំចេញសំលៀកបំពាក់ និងអង្ករ កើន ២,៥% ដល់ ២២៧,៧លានដុល្លារ និង ៥៦% ដល់ 0,៣លានដុល្លារ រីឯការនាំចេញកៅស៊ូ និងត្រី ធ្លាក់ចុះ ៣៧% មកត្រឹម ២,៧លានដុល្លារ និង ៤0% មកត្រឹម 0,២លានដុល្លារ ។ បើធៀបនឹងខែដូចគ្នាឆ្នាំ២00៦ ការនាំចេញសរុប កើន ២៧% ក្នុងនេះ ការនាំចេញសំលៀកបំពាក់ កើន ២៧% ប៉ុន្តែការនាំចេញត្រី កៅស៊ូ និងអង្ករ ធ្លាក់ចុះ ១,៩% ២៣% និង ៤៨% ។

Cambodia's main exports in February 2007 increased by 6.0 percent from the previous month, to USD 244.2 m. Of the total exports, garment and rice exports rose by 2.5 percent to USD 227.7 m and 56 percent to USD 0.3 m, respectively, while rubber and fish exports decreased by 37 percent to USD 2.7 m, and 40 percent to USD 0.2 m, respectively. Compared to the same month in 2006, total exports rose by 27 percent. Garment exports increased by 27 percent, and fish, rubber and rice exports decreased by 1.9 percent, 23 percent and 48 percent, respectively.

**Cambodia: Main Exports**
December 2005 – February 2007




Source: Customs and Excise Department

នៅខែកុម្ភៈ ២00៧ ការនាំចូលបារី និងដែក ធ្លាក់ចុះ ១៧% និង ២0% ធៀបនឹងខែមុន មកត្រឹម ៣១,៣ពាន់លានរៀល និង ២0,១ពាន់លានរៀល រីឯការនាំចូលស៊ីម៉ង់ត៍ កើន 0,៤% ដល់ ២១,៨ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នាឆ្នាំ២00៦ ការនាំចូលដែក កើនមួយជាបី ហើយ ការនាំចូលស៊ីម៉ង់ត៍ កើន ២៣% រីឯការនាំចូលបារី ធ្លាក់ចុះ ១១% ។

In February 2007, cigarette and steel imports decreased by 17 percent and 20 percent from the preceding month to KHR 31.3 bn and KHR 20.1 bn, respectively, while cement imports increased by 0.4 percent to KHR 21.8 bn. Compared to the same month in 2006, steel imports tripled and cement imports rose by 23 percent, while cigarette imports declined by 11 percent.

**Imports: Cigarettes & Construction Material**
December 2005 – February 2007




Source: Customs and Excise Department

នៅខែកុម្ភៈ ២00៧ ការនាំចូលសាំង ធ្លាក់ចុះ 0,៣% មកត្រឹម ៤៤.២00តោន រឺស្មើនឹង ១៧,៨ពាន់លានរៀល រីឯការនាំចូលម៉ាស៊ូត កើន 0,៣% ដល់ ១៤.២00តោន រឺ ៤៥,៨ពាន់លានរៀល ។ ប៉ុន្តែការនាំចូលសាំង និងម៉ាស៊ូត កើន 0,៣% និង 0,១% ធៀបនឹងខែដូចគ្នាឆ្នាំ២00៦ ។

Petrol imports were down by 0.3 percent to 44,200 tonnes or KHR 17.8 bn in February 2007, while diesel imports were up by 0.3 percent to 14,200 tonnes or KHR 45.8 bn. Volumes of both petrol and diesel imports, however, increased by 0.3 percent and 0.1 percent, respectively, from the same month in 2006.

**Imports: Petroleum Products**
December 2005 – February 2007




Source: Customs and Excise Department

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ថវិកាចរន្ត មានអតិរេក ៣២,៤ពាន់លានរៀល នៅត្រីមាសទី៤ ២០០៦ ធៀបនឹងអតិរេក ១១០,៤ពាន់លានរៀល នៅត្រីមាសមុន និងឱនភាព ៤៣,៣ពាន់លានរៀល នៅត្រីមាសដូចគ្នា ២០០៥។ ចំណាយចរន្តមានកំរិត ៩៥% នៃចំណូលចរន្តសរុបនៅត្រីមាសទី៤នេះ ។

The current budget surplus was KHR 32.4 bn in the fourth quarter 2006, compared to the surplus of KHR 110.4 bn in the previous quarter and the deficit of KHR 43.3 bn in the same quarter 2005. Current expenditure was 95 percent of total current revenue in this fourth quarter.

**Current Budget Operations**
2002 Q2 – 2006 Q4




*Note: Provisional for2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅត្រីមាសទី៤ ២០០៦ ចំណូលថវិកាចរន្ត កើន ១៨% ធៀបនឹងត្រីមាសមុន ដល់ ៨៤៤,៨ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ និងចំណូលពន្ធនាំចេញនាំចូល កើន ២១% និង ២៣% ដល់ ១៨៣,១ពាន់លានរៀល និង ៤៥២,៦ពាន់លានរៀល រីឯចំណូលពីពន្ធក្នុងស្រុក កើន ៥,៤% ដល់ ២០៩,២ពាន់លានរៀល ។ ធៀបនឹងពេលដូចគ្នាឆ្នាំ២០០៥ ចំណូលចរន្តកើន ២០% ចំណូលពន្ធនាំចេញនាំចូល ចំណូលមិនមែនពន្ធ និងចំណូលពន្ធក្នុងស្រុក កើន ៧,២% ២៤% និង ៥៩% ។

In the fourth quarter 2006, current budget revenue increased by 18 percent from the previous quarter to KHR 844.8 bn. Non-tax, and import and export tax revenue rose by 21 percent and 23 percent to KHR 183.1 bn and KHR 452.6 bn, respectively, whereas revenue from domestic tax increased by 5.4 percent to KHR 209.2 bn. Compared to the same period 2005, current revenue rose by 20 percent; import and export tax, non-tax and domestic tax increased by 7.2 percent, 24 percent and 59 percent, respectively.

**Current Budget Revenue**
2004 Q3 – 2006 Q4




*Note: Provisional for 2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅត្រីមាសទី៤ ២០០៦ ចំណាយថវិកាចរន្ត កើន ៣៨% ធៀបនឹងត្រីមាសមុន ដល់ ៨០០,៦ពាន់លានរៀល ។ ចំណាយលើ សន្តិសុខនិងការពារជាតិ រដ្ឋបាលទូទៅ និងរដ្ឋបាលសេដ្ឋកិច្ច កើន ៩,៥% ១៣% និង ៤៨% ដល់ ១៧០,១ពាន់លានរៀល ១៣៥,៣ពាន់លានរៀល និង ៩២,៥ពាន់លានរៀល ។ ចំណាយលើរដ្ឋបាលសង្គម កើន ៧៥% ដល់ ៣៤៣,៨ពាន់លានរៀល ។

Current budget expenditure increased by 38 percent from the preceding quarter to KHR 800.6 bn in the fourth quarter 2006. Expenditure on defense and security, general administration and economic administration rose by 9.5 percent, 13 percent and 48 percent to KHR 170.1 bn, KHR 135.3 bn and KHR 92.5 bn, respectively, while spending on social administration increased by 75 percent to KHR 343.8 bn.

**Current Budget Expenditure**
2004 Q2 – 2006 Q4




*Note: Provisional for 2006*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែកុម្ភៈ ឆ្នាំ២០០៧ ការនាំចេញទំនិញរបស់US ធ្លាក់ចុះ រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និងជប៉ុន កើនឡើង ។ ការនាំចេញទំនិញរបស់ US ធ្លាក់ចុះ ២,៦% ធៀបនឹងខែមុន មកត្រឹម ៨៨,៤៤ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និងជប៉ុន កើន ១,២% និង ៦,៤% ធៀបនឹងខែមុន ដល់ ១៦០,៩២ពាន់លានដុល្លារ និង ៥៣,០៧ពាន់លានដុល្លារ ។

In February 2007, goods exports of the US decreased, while exports of the Euro zone and Japan increased. US goods exports decreased by 2.6 percent from the previous month to USD88.44 bn. Goods exports of the Euro zone and Japan rose by 1.2 percent and 6.4 percent, respectively, from the previous month, to USD160.92 bn and USD53.07 bn.

**Goods Exports: US, Euro zone & Japan**
February 2006 – February 2007




Sources: BEA, Eurostat and JETRO

នៅខែកុម្ភៈ ២០០៧ ចិនមានអតិរេកពាណិជ្ជកម្ម ២៣,៧៦ពាន់លានដុល្លារ ធៀបនឹង អតិរេក ១៧,៧៤ពាន់លានដុល្លារ នៅខែមករា ។ អតិរេកដ៏ធំនេះ បណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃការនាំចូល ធៀបនឹងការនាំចេញ ។ ការនាំចេញសរុប ធ្លាក់ចុះ ៥,២% ធៀបនឹងខែមុន មកត្រឹម ៨២,១០ ពាន់លានដុល្លារ រីឯការនាំចូលសរុប ធ្លាក់ចុះ ១៧% មកត្រឹម ៥៨,៣៤ពាន់លានដុល្លារ ។

In February 2007, China recorded a trade surplus of USD23.76 bn, compared to USD17.74 bn in January. The larger surplus was due to a greater decline in imports than exports. Total exports decreased by 5.2 percent from the previous month, to USD82.10 bn, while total imports decreased by 17 percent to USD58.34 bn.

**External Trade: China**
February 2006 – February 2007




Sources: National Bureau of Statistics of China

នៅខែកុម្ភៈ ២០០៧ ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ២,០០ពាន់លានដុល្លារ ធៀបនឹងអតិរេក ១,៧៣ពាន់លានដុល្លារ នៅខែមករា ២០០៧ ។ ការនាំចេញសរុប ធ្លាក់ចុះ ១២% ធៀបនឹងខែមុន មកត្រឹម ១០,៨២ពាន់លានដុល្លារ រីឯការនាំចូលសរុប ធ្លាក់ចុះអស់ ១៧% មកត្រឹម ៨,៨២ពាន់លានដុល្លារ ។

In February, Malaysia recorded a trade surplus of USD2.00 bn, compared to USD1.73 bn in January. Total exports decreased by 12 percent from the previous month to USD10.82 bn, while total imports decreased by 17 percent to USD8.82 bn..

**External Trade: Malaysia**
February 2006 – February 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅUS កើន ២,៤% ក្នុងរយៈមួយឆ្នាំដល់ខែកុម្ភៈ ឆ្នាំ២០០៧ ។ យោងតាមក្រសួងការងារUS កំណើននេះបណ្តាលមកពី ការឡើងថ្លៃម្ហូបអាហារ ការថែទាំសុខភាព និងការស្នាក់នៅ ។ នៅអំឡុងពេលដូចគ្នា អត្រាអតិផរណា មានកំរិត ១,៨% នៅតំបន់អឺរ៉ូ និង -០,២% នៅជប៉ុន ។

US consumer prices increased by 2.4 percent in the year to February 2007. According to the U.S Department of Labor, this increase was due to higher charges for food, medical care, and housing. During the same period, the inflation rate was 1.8 percent in the Euro zone and -0.2 percent in Japan.

**Inflation Rate: US, Euro zone & Japan**

(change from a year ago)




*Note: The latest data available are for Feb. 2007*
Sources: IMF and *Economist* (April 19th 2007)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ០,៨% ក្នុងរយៈ១ឆ្នាំដល់ខែកុម្ភៈ ឆ្នាំ២០០៧ ប៉ុន្តែនៅទាបជាងកំណើន ២,០% នាខែមុន ។ រឿងនេះ បណ្តាលមកពីការលើកលែងការបង់ថ្លៃជួលផ្ទះរដ្ឋ ។ នៅអំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់ទាំងនៅចិន និងកូរ៉េខាងត្បូង កើន ២,៧% និង ២,២% ។

Hong Kong’s consumer prices rose by 0.8 percent in the year to February 2007, smaller than the 2.0 percent increase of a month earlier. This was attributable to the waiver of public housing rentals by the Housing Authority and Housing Society. During the same period, consumer prices in both China and South Korea increased by 2.7 percent and 2.2 percent respectively.

**Inflation Rate: China, Hong Kong & South Korea**

(change from a year ago)




*Note: The latest data available are for Feb. 2007*
Sources: IMF and *Economist* (April 19th 2007)

នៅខែមករា ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី មានកំរិត ០,៦% ខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះបណ្តាលជាសំខាន់មកពីការឡើងថ្លៃម្ហូបអាហារ ការអប់រំ ការថែទាំសុខភាព និងការលំហែកំសាន្ត ។ នៅអំឡុងពេលដូចគ្នា អតិផរណាក្នុងរយៈមួយឆ្នាំ មានកំរិត ៣,១% នៅម៉ាឡេស៊ី និង ២,៣% នៅថៃ ។

Singapore's consumer price index in January 2007 was 0.6 percent higher than for the same month a year earlier. According to Singapore’s Department of Statistics, this largely reflected higher costs for food, education, healthcare and recreation. During the same period, the year-on-year inflation rate was 3.1 percent in Malaysia and 2.3 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(change from a year ago)




*Note: The latest data available are for Feb. 2007*
Sources: IMF and *Economist* (April 19th 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែមេសា ២០០៧ ដុល្លារUS មានការឡើងចុះថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ ទល់នឹងប្រាក់អឺរ៉ូ ដុល្លារUS ប្តូរបាន ០,៧៤អឺរ៉ូ/ដុល្លារUS រឺធ្លាក់ចុះ ២% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារUS ប្តូរបាន ១១៨,៩ យ៉េន/ដុល្លារUS រឺឡើងថ្លៃ ១,៤% ធៀបនឹងខែមុន ។

In April 2007, the movement of the US dollar against most major currencies was mixed. Against the euro, it traded at 0.74 EUR/USD, a 2 percent fall from a month earlier. Against the Japanese yen, it exchanged at 118.9 JPY/USD, a 1.4 percent rise compared to the preceding month.

**EUR & JPY Per USD**

April 06 – April 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែមេសា ២០០៧ ប្រាក់វ៉ុនកូរ៉េខាងត្បូង ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៩៣០,៦៩វ៉ុន/ដុល្លារUS ធៀបនឹង ៩៤២,៨៨វ៉ុន/ដុល្លារUS នៅខែមីនា ២០០៧ ។ នៅអំឡុងពេលដូចគ្នា ដុល្លារហុងកុង នៅថេរទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៨២ដុល្លារហុងកុង/ដុល្លារUS ។

In April 2007, the South Korean won appreciated slightly against the US dollar, trading at 930.69 KRW/USD against 942.88 KRW/USD in March 2007. During the same period, the Hong Kong dollar was steady against its US counterpart, trading at 7.82 HKD/USD.

**KRW & HKD Per USD**

April 06 – April 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែមេសា ឆ្នាំ២០០៧ ដុល្លារសិង្ហបុរី បន្តកើនឡើងទល់នឹងដុល្លារUS បាន៧ខែជាប់ៗគ្នា ដោយប្តូរបាន ១,៥១៥ដុល្លារសិង្ហបុរី/ដុល្លារUS ។ ប្រាក់បាតថៃ ក៏ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដែរ ដោយប្តូរបាន ៣២,៤២បាត/ដុល្លារUS រឺឡើងថ្លៃ ០,៧% ធៀបនឹងខែមីនា ២០០៧ ។

In April 2007, the Singapore dollar continued to strengthen against the US dollar for a seventh consecutive month, trading at 1.515 SGD/USD. The Thai baht also slightly advanced against the US dollar, exchanging at 32.42 THB/USD, a 0.7 percent appreciation from March 2007.

**THB & SGD Per USD**

April 06 - April 07 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែមីនា ២០០៧ ថ្លៃអង្ករពិភពលោក កើនឡើង ដោយសារជាសំខាន់ មានតំរូវការខ្លាំងនៅអាស៊ី ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនដល់ ១៣៩,៨ពិន្ទុ ធៀបនឹង ១៣៧,៣ពិន្ទុ នៅខែកុម្ភៈ ។ នៅថៃ ថ្លៃអង្ករ 100%B កើនពី ២៩៣,៨៧ដុល្លារ/តោន នៅខែកុម្ភៈ ដល់ ២៩៩,៣១ដុល្លារ/តោន ។ នៅUS ថ្លៃអង្ករនាំចេញ ធ្លាក់ចុះ ១,១% ធៀបនឹងខែមុន មកត្រឹម ៣៩៤,៥៥ដុល្លារ/តោន ។

In March, world rice prices increased, largely due to strong demand in Asia. The International Prices Index (IPO) rose to 139.8, against 137.3 in February. In Thailand, the price of Thai 100%B rose from USD293.87 per tonne in February to USD299.31. In the United States, the export price decreased by 1.1 percent from last month to USD394.55 per tonne.

**Rice: International Prices Index & Export Prices**
March 2006 – March 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែមេសា ២០០៧ សណ្តែកសៀង និង ពោត ធ្លាក់ថ្លៃ ។ សណ្តែកសៀង លក់ថ្លៃ ២៤៧,៣២ដុល្លារ/តោន ដោយធ្លាក់ពី ២៥៤,៥០ដុល្លារ/តោន នៅខែមីនា ២០០៧ ។ ពោត លក់ថ្លៃ ១៣៩,៣៥ដុល្លារ/តោន ធៀបនឹង ១៥៥,៦២ដុល្លារ/តោន នៅខែកុម្ភៈ ២០០៧ ។ ចំពោះថ្លៃប្រេងឆា នៅខែមីនា ២០០៧ នៅមិនទាន់មានចេញផ្សាយនៅឡើយទេ ។

In April 2007, the prices of soybeans and maize decreased. Soybeans sold at USD247.32 per tonne, down from USD254.50 in March. Maize was USD139.35 per tonne, down from USD155.62 in February. The price of palm oil in March is currently not available.

**Prices: Soybeans, Maize & Palm Oil**
April 2006 – April 2007




Source: Food and Agriculture Organisation (FAO)

នៅខែមេសា ២០០៧ ថ្លៃប្រេងឆៅ សាំង និងម៉ាស៊ូត កើនឡើង ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៤,៤១ដុល្លារ/ធុង ទល់នឹង ៥៧,៩៩ដុល្លារ/ធុង នៅខែមីនា ។ សាំងធម្មតា នៅ US Gulf Coast (អុកតាន ៨៧) ឡើងថ្លៃ ១៥% ធៀបនឹងខែមុន ដល់ ៥៥,៣៦សេន/លីត្រ ។ ថ្លៃម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) កើន ៩,៥% ធៀបនឹងខែមុន ដល់ ៥៤,២៩សេន/លីត្រ ។

In April, the prices of crude oil, petrol and diesel increased. The OPEC spot price for crude oil was USD64.41 per barrel, against USD57.99 in March. Regular petrol (87 octane) prices on the US Gulf Coast rose by 15 percent from the previous month to 55.36 cents per litre. Diesel (low sulphur No.2) on the US Gulf Coast also increased by 9.5 percent from the previous month, to 54.29 cents per litre.

**Prices: Crude Oil, Petrol & Diesel**
April 2006 – April 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច/Economic News

**កម្ពុជាអនុម័តច្បាប់ស្តង់ដារ :** នៅថ្ងៃទី ២៥ មេសា ២០០៧ រដ្ឋសភាបានអនុម័តច្បាប់ ស្តីពីស្តង់ដាររបស់កម្ពុជា ដែលគេរំពឹងថា នឹងធ្វើឱ្យទំនិញនាំចេញនាំចូលរបស់កម្ពុជាមានស្តង់ដារគុណភាពច្បាស់លាស់ ។ លោក អ៊ិត ប្រាំង រដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានបញ្ជាក់ថា "ច្បាប់នេះនឹងជំរុញសហគ្រិន និងផលិតករក្នុងតំបន់ឱ្យផលិតទំនិញមានស្តង់ដាររួមមួយ" ។ លោកលើកបន្ថែមថា "វាក៏លើកទឹកចិត្តផងដែរ ឱ្យអ្នកផលិតធ្វើការប្រកួតប្រជែងគ្នាលើមូលដ្ឋានយុត្តិធម៌ នៅក្នុងទីផ្សារ" ។ យោងតាមច្បាប់នេះ នឹងមានបង្កើត វិទ្យាស្ថានស្តង់ដារកម្ពុជា មួយ ដើម្បីជួយបញ្ជាក់បំភ្លឺពី ស្តង់ដារគុណភាពនៃផលិតផលនាំចេញនាំចូល ។ អ្នកដែលប្រើប្រាស់សញ្ញាស្តង់ដារកម្ពុជាដោយខុសច្បាប់ នៅលើផលិតផលរបស់ខ្លួន ត្រូវមានទោសជាប់ពន្ធនាគារពី ៦ថ្ងៃ ទៅ ១ខែ និងត្រូវផាកពិន័យ ពី ១២៥ ទៅ ៥០០ដុល្លារអាមេរិក ។ ច្បាប់នេះបានអនុម័តឡើង ដើម្បីបំពេញតាមលក្ខខណ្ឌរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលកម្ពុជាបានចូលជាសមាជិកតាំងពីឆ្នាំ២០០៤ ។

**Cambodia Passes Standard Law**: The Cambodian National Assembly approved the Law of Standards of Cambodia, which is expected to standardise the quality of the kingdom's imported and exported goods, on April 25th 2007. "This law will urge our local enterprises and producers to produce commodities of a unified standard," said Ith Prang, secretary of state at the Ministry of Industry, Mines and Energy. "It will also encourage all manufacturers to compete with each other on an equal basis in market," he added. Under the law, an Institute of Standards of Cambodia (ISC) will be established to help clarify the quality standard of imported and exported products. Meanwhile, anyone who illegally uses the Standard of Cambodia mark on their products will be sentenced to a jail term of between six days and one month, in addition to a fine of 125 to 500 U.S. dollars. The law was passed to implement WTO conditions, which Cambodia entered in 2004. (Cited from *Xinhua*, 25 March 2007)

**បណ្តាប្រទេសនៅតំបន់ទន្លេមេគង្គ បានចុះកិច្ចព្រមព្រៀងខាងដឹកជញ្ជូនដ៏សំខាន់មួយ :** បណ្តាប្រទេសនៅតំបន់ទន្លេមេគង្គបានចុះកិច្ចព្រមព្រៀងមួយ ដើម្បីជួយសំរួលចលនាមនុស្សនិងទំនិញឆ្លងកាត់ព្រំដែន ។ កិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែន បានកែលំអតីវិមបទប្បញ្ញត្តិ និងបែបបទសំរាប់ការឆ្លងកាត់ព្រំដែនក្នុងមហាអនុតំបន់មេគង្គ ។ កិច្ចព្រមព្រៀងសំដៅបង្កភាពងាយស្រួលដល់ការឆ្លងកាត់ព្រំដែន ដោយលុបបំបាត់ រឺកាត់បន្ថយរបាំងអរូបិយផ្សេងៗ ដូចជា ការត្រួតពិនិត្យគយមានតែមួយកន្លែង ការជួយធ្វើទិដ្ឋាការសំរាប់អ្នកពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងបែបបទសំដៅកាត់បន្ថយការត្រួតពិនិត្យលើយានយន្ត ។ លោក Arjun Thapan អគ្គនាយកនៃធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅអាស៊ីអាគ្នេយ៍ បាននិយាយថា "កំណែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការកាត់បន្ថយរបាំងពាណិជ្ជកម្ម មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រសំរាប់ប្រទេសនៅមហាអនុតំបន់មេគង្គ"។

**Mekong countries complete landmark transport agreement:** The countries of the Mekong region completed an agreement to facilitate movement of people and goods across borders. The Cross Border Transport Agreement streamlines the regulations and procedures for crossing borders in the Greater Mekong Subregion of China, Cambodia, Laos, Myanmar, Thailand, and Vietnam. The agreement, designed to ease border crossings by removing or reducing non-physical barriers, includes measures such as single-stop customs inspections, visa assistance for those involved in cross-border trade, and facilities to reduce inspections of vehicles. "Improving transport infrastructure and lowering trade barriers are crucial to growing the economies of the Mekong subregion and reducing poverty," said Arjun Thapan, director general of the Asian Development Bank's (ADB) Southeast Asia department. (Cited from *Xinhua*, 20 March 2007)

**កំពង់ផែថ្មីនៅក្រុងព្រះសីហនុ នឹងធ្វើឱ្យមានកំណើនពាណិជ្ជកម្ម :** សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា កំពង់ផែថ្មីមួយទៀត នឹងត្រូវសាងសង់នៅក្រុងព្រះសីហនុ ដើម្បីជួយបំរើដល់កំណើនពាណិជ្ជកម្ម ។ សម្តេច បានថ្លែងកាលពីថ្ងៃទី៤ មេសា ២០០៧ នៅឯពិធីសម្ពោធនៅក្រុងព្រះសីហនុថា "កំពង់ផែបច្ចុប្បន្នមិនទាន់គ្រប់គ្រាន់សំរាប់បំរើដល់កំណើនសេដ្ឋកិច្ចទេ ។ ជាមួយនឹងគោលនយោបាយបើកចំហជើងមេឃ យើងនឹងសាងសង់កំពង់ផែសមុទ្រមួយទៀតសំរាប់បំពេញតំរូវការនាំចេញនាំចូល" ។ កំពង់ផែនេះ នឹងត្រូវសាងសង់ដោយក្រុមហ៊ុនអែតវូដ អាហ៉រណេនីហ៉រណេ ខូអេលធីឌី ដែលជាក្រុមហ៊ុនកម្ពុជា ដោយមានការចូលរួមសហការជាមួយក្រុមហ៊ុនជប៉ុន ។ សម្តេចបានបន្ថែមទៀតថា ការសាងសង់កំពង់ផែនឹងចាប់ដំណើរការនៅខែកក្កដា ហើយគ្រោងរួចរាល់នៅឆ្នាំ២០១២ ។ លោក សាយ ហាក់ អភិបាលក្រុងព្រះសីហនុ បានលើកថា កំពង់ផែនឹងសាងសង់នៅឃុំអូត្រេះ ស្រុកស្ទឹងហាវ ។

**New Sihanoukville Port Will Serve Increase In Trade:** Prime Minster Hun Sen announced that another seaport will be built in Sihanoukville to accommodate the increase in trade. "The current port is not sufficient to serve our economic improvement. With the open sky, land and water policy, we've allowed another seaport here for export and import needs," he said on Wednesday (04 April 2007) at an inauguration ceremony in Sihanoukville. The port will be built by Attwood Import Export Co Ltd., a Cambodian company, together with a Japanese firm, Hun Sen said, adding that construction will begin in July and should be completed by 2012. Sihanoukville Governor Say Hak said the port will be built in Stung Haw district's O'Tres commune. (Cited from *The Cambodia Daily*, 06 April 2007)